មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0122**

**សម្ភាសន៍ជាមួយឈ្មោះ អ៊ុក ឆន ភេទប្រុស អាយុ៤៧ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម**

**ស្រុកកំណើតនៅភូមិស្រុកឃ្លោក ឃុំព្រះមូរ ស្រុកបាកាន ខេត្តពោធិ៍សាត់**

**សព្វថ្ងៃរស់នៅភូមិជន្លៀសដៃ ឃុំគោកកថិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:១២:៤៥**

**៣២ទំព័រ**

ដានីៈ អញ្ចឹងលោកពូខ្ញុំសុំស្គាល់ឈ្មោះលោកពូពីកំណើត លោកពូឈ្មោះអី?

ឆនៈ ឈ្មោះអ៊ុក ឆន ។

ដានីៈ ចុះឈ្មោះបដិវត្តន៍?

ឆនៈ ឈ្មោះដួង សំអុល ។

ដានីៈ ដួង សំអុល?

ឆនៈ បាទ!

ដានីៈ ពូដូរឈ្មោះពីអង្កាល់?

ឆនៈ ដូរតាំងពី៧៧ ។

ដានីៈ ៧៧?

ឆនៈ បាទ! ពេលទៅព្រំដែន ទៅស្រុកប្រសូត្រ ។

ដានីៈ ទៅស្រុកប្រសូត្រខាងស្វាយរៀង?

ឆនៈ បាទ!

ដានីៈ ដូរឈ្មោះដួង សំអុលហ្នឹងប្រើដល់សព្វថ្ងៃហ្នឹង?

ឆនៈ បាទ!

ដានីៈ ដល់អ៊ុក ឆននេះអត់ប្រើទេ?

ឆនៈ បាទ!

ដានីៈ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ឆនៈ	អាយុ៥៦ ។

ដានីៈ	អាយុ៥៦ឆ្នាំ?

ឆនៈ	បាទ!

ដានីៈ	ស្រុកកំណើតនៅណាដែរ?

ឆនៈ	នៅភូមិចន្រ្ទានដែក ។

ដានីៈ	ឃុំអី?

ឆនៈ	សំរោងទង ស្រុកសំរោងទង ។

ដានីៈ	សព្វថ្ងៃពូរស់នៅភូមិអីដែរ?

ឆនៈ	ភូមិថ្មដែកកេះ ។

ដានីៈ	ឃុំ?

ឆនៈ	ឃុំបន្ទាយឆ្មា ។

ដានីៈ	ស្រុក?

ឆនៈ	ថ្មពួក ។

ដានីៈ	ខេត្ត?

ឆនៈ	ខេត្តបន្ទាយមានជ័យ ។

ដានីៈ	សព្វថ្ងៃពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

ឆនៈ	ខ្ញុំអត់មានធ្វើអីទេ ធ្វើតែមេភូមិហ្នឹង ។

ដានីៈ	ធ្វើមេភូមិ?

ឆនៈ	បាទ!

ដានីៈ	ពូមានធ្វើស្រែចំការឬអត់?

ឆនៈ	អត់ទេ ព្រោះវាអត់មានដីមិនដឹងជាធ្វើអី ដីនោះដីតំបន់ព្យាក្រិតមិនហ៊ានលូក ព្រោះយើងអ្នកច្បាប់អ្នកការងាររទៅប៉ះពាល់អី ។

ដានីៈ	ចុះប្រពន្ធពូគាត់ឈ្មោះអីដែរ?

ឆនៈ	ឈ្មោះអិន សាម៉េន តែក្រៅគេហៅតែអ៊ិន ម៉ៅ ។

ដានីៈ	គេហៅម៉ៅ?

ឆនៈ	បាទ!

ដានីៈ	ចុះឥលូវហ្នឹងឈ្មោះម៉ៅដែរ?

ឆនៈ ឥលូវគេអត់សូវស្គាល់អាឈ្មោះដើមហ្នឹងទេគេហៅតែម៉ៅៗ ។

ដានីៈ អញ្ចឹងគេហៅគាត់ម៉ៅ?

ឆនៈ ជួនកាលគេហៅគាត់ម៉ែអាត ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ឆនៈ គាត់អាយុ៤៩ឆ្នាំ ។

ដានីៈ គាត់អ្នកស្រុកណាដែរ?

ឆនៈ និយាយភូមិណា៎ គឺភូមិព្រៃដើង ។

ដានីៈ ភូមិព្រៃដើង?

ឆនៈ បាទ!

ដានីៈ ចុះឃុំ?

ឆនៈ ឃុំគោកព្រិច ។

ដានីៈ ស្រុក?

ឆនៈ ស្រុកគិរីវង្ស ។

ដានីៈ ខេត្តតាកែវ?

ឆនៈ បាទ!

ដានីៈ សព្វថ្ងៃពូមានកូនចៅប៉ុន្មាននាក់ហើយ?

ឆនៈ ខ្ញុំមានកូនចៅ៧នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឆនៈ ស្រីមានតែមួយ ហើយប្រុស៦នាក់ ។

ដានីៈ កូនពូធំៗអស់ហើយ?

ឆនៈ ធំៗអស់ហើយ ។

ដានីៈ ចុះឪពុកពូឈ្មោះអីដែរ?

ឆនៈ ឈ្មោះអ៊ុក ឆុន ។

ដានីៈ សព្វថ្ងៃគាត់ស្លាប់អស់ហើយ?

ឆនៈ ស្លាប់អស់ហើយ ។

ដានីៈ ស្លាប់តាំងពីអង្កាល់?

ឆនៈ ស្លាប់មុនសម័យរដ្ឋប្រហារ ។

ដានី៖ គាត់ស្លាប់ដោយសារមូលហេតុអី?

ឆន៖ ឪពុកមែន?

ដានី៖ បាទ!

ឆន៖ ដូចថាអបិយជំនឿគាត់ត្រូវអំពើគេ ។

ដានី៖ ចុះម្ដាយ?

ឆន៖ ម្ដាយឈ្មោះដាន់ ម៉ាលីស ។

ដានី៖ គាត់នៅរស់ឬក៏ស្លាប់ហើយ?

ឆន៖ គាត់គ្រោះថ្នាក់ចរាចណ៍ ។

ដានី៖ ឆ្នាំណាទៅ?

ឆន៖ ឆ្នាំ៧០ ។

ដានី៖ ឆ្នាំ៧០?

ឆន៖ បាទ!

ដានី៖ នៅណា?

ឆន៖ នៅចោមចៅ ។

ដានី៖ គាត់ទៅចោមចៅ?

ឆន៖ បន្ទាយនៅហ្នឹងគាត់តាមប្ដីគាត់ ។

ដានី៖ គ្រោះថ្នាក់ចរាចរណ៍ហ្នឹងយ៉ាងម៉េច?

ឆន៖ គ្រោះថ្នាក់ចរាចរណ៍ហ្នឹងឡានបុក ។

ដានី៖ ឡានបុក?

ឆន៖ បាទ! ហើយស្លាប់ហ្នុង ។

ដានី៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ឆន៖ មានបងប្អូនបង្កើត៣នាក់

ដានី៖ ៣នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឆន៖ ប្រុស២នាក់ ស្រី១នាក់ ។

ដានី៖ ពូកូនទីប៉ុន្មាន?

ឆន៖ ខ្ញុំកូនទី១ ។

ដានី៖ កូនបងគេ?

ឆន៖ បាទ!

ដានី៖ ពូមានបានរៀនសូត្រទេកាលពីក្មេងៗ?

ឆន៖ កាលនៅក្មេងរៀនបានតិចណាស់ រៀនបានត្រឹមថ្នាក់ទី១០ហ្នឹង ។

ដានី៖ រៀនបានត្រឹមទី១០?

ឆន៖ បាទ!

ដានី៖ រៀននៅសាលាណា?

ឆន៖ រៀននៅសាលាវត្តអន្តជ្រ័យ ។

ដានី៖ អន្តជ្រ័យ?

ឆន៖ បាទ! ខាងជើងព្រៃផ្តៅ ។

ដានី៖ ពូឈប់រៀនឆ្នាំណា?

ឆន៖ ខ្ញុំឈប់រៀនពេលឆ្នាំរដ្ឋប្រហារ ថ្ងៃរដ្ឋប្រហារហ្នឹងគេចាប់ទាហានអញ្ចឹងនៅមិនបានទាល់តែចេញ ឲ្យកាតកូនសិស្សគេមើលគេថាគេមិនយកទេ គេយកមនុស្ស ។

ដានី៖ គេថាអញ្ចឹង?

ឆន៖ បាទ! កាលនោះពួកកងពលលេខ១៣ ដែលនៅឆ្បាមន ។

ដានី៖ កងពលខាងលន់ នល់?

ឆន៖ រត់ចោលស្រុកត្រឹមនោះឯង នៅវាមិនបានដេកតែព្រៃ ។

ដានី៖ ពូរត់ទៅណាទៅ?

ឆន៖ ខ្ញុំរត់ម៉ោស្នាក់នៅវត្តទំពូង ។

ដានី៖ ហើយម៉េចទៀតទៅ?

ឆន៖ ខ្ញុំរត់ម៉ោនៅហ្នឹងធ្វើឈ្លបហ្នឹងគេ ។

ដានី៖ ធ្វើនៅឆ្នាំ៧០ហ្នឹងមែន?

ឆន៖ បាទ!

ដានី៖ ឈ្លបខាងណា?

ឆន៖ ឈ្លបខាងរណៈសេរ្សរួបរួមជាតិហ្នឹងណា៎ ។

ដានី៖ កាលហ្នឹងខែប៉ុន្មានដែលពូចូលធ្វើឈ្លបហ្នឹង?

ឆន៖ កាលចូលធ្វើឈ្លបហ្នឹងដូចជាខែ៣ ។

ដានី៖ ខែ៣ ឆ្នាំ៧០?

ឆនៈ បាទ! វាគ្រាន់តែខុសថ្ងៃបន្តិចបន្តួចហ្នឹង កាលហ្នឹងដូចជាថ្ងៃទី១៨ខែ៣ ។

ដានីៈ បាទ!

ឆនៈ ដល់ពេលគេធ្វើរដ្ឋប្រហារខ្ញុំងពេកទៅប្រហែលជាថ្ងៃទី២០ បានខ្ញុំរត់ចេញ ។

ដានីៈ ហើយកាលពូម៉ោធ្វើឈ្លបហ្នឹងពូម៉ោតាមពីណាគេដែរ?

ឆនៈ ម៉ោតាមរយៈបណ្តាញៗដែលគេបន្តប់ក្នុងភូមិ កាលហ្នឹងគេខ្លាចយើងមិនស្គាល់ផ្លូវ ហើយបើគេឲ្យយើងម៉ោទាល់តែពេលថ្ងៃបានគេឲ្យយើងម៉ោ ព្រោះកាលហ្នឹងនៅខាងលិចភ្នំពេញហ្នឹងឈ្លបវាច្រើន ដូចកងទ័ពដែលគេចុះម៉ោអាពួកអាវខ្មៅ ពេលគេចុះម៉ោអញ្ចឹងគេទំនាក់ទំនងដូចថារត់ទៅនេះរត់ទៅនោះមិនរួច បានពូមួយនោះម៉ោពីភូមិដែលគេហៅថាភូមិដូងៗ ហើយគាត់ថាទៅនេះជាមួយអញទៅ នៅនេះវាមិនសមហើយក៏បានទៅជាមួយគាត់ទៅ ដល់ពេលទៅក៏នៅហ្នឹងរហូតហើយជួបជាមួយភូមិគេភូមិគេមិនឲ្យនៅគេឲ្យត្រលប់ម៉ោរៀននៅអមលាំង ។

ដានីៈ គេឲ្យម៉ោនៅអមលាំង?

ឆនៈ ម៉ោរៀនបច្ចេកទេសនៅអមលាំងហ្នឹង ។

ដានីៈ ពេលណាបានពូម៉ោរៀនបច្ចេកទេសនៅអមលាំងហ្នឹង?

ឆនៈ កាលហ្នឹងខ្ញុំនៅឈ្លបហ្នឹងវាបានកន្លងផុតមួយឆ្នាំហើយ
ហើយម៉ោនៅអមលាំងរៀនបច្ចេកទេស ។

ដានីៈ បាទ!

ឆនៈ ៧១ ,៧២ ចេញដើរវៃ ។

ដានីៈ ហាត់ទាហាន?

ឆនៈ បាទ! ឲ្យដើរប្រតិបត្តិការ ដើរស៊ើបការ ពីដើមវាចំរុះគេមើលទៅតាមសមត្ថភាពយើង ថាសមត្ថភាពយើងអាចធ្វើអីបាន ក៏យើងអ្នកនេះមានតែកម្លាំងមានតែកដូចគោ គេរុញឲ្យទៅតែស្លាប់ហ្នឹង កាលឆ្នាំ៧៥អាជីតបញ្ចប់ហ្នឹងម៉ាជួរអន្លុក្រពើ ភ្នំធំអីហ្នឹង វៃគ្នានៅមួយជួរអន្លុស្នួលថ្នល់ទទឹងណា ហើយខ្ញុំនៅមួយជួរម៉ាតពង ពោត្រពាំងកុងខាងជើង ។

ដានីៈ ហើយយ៉ាងម៉េចទៀតទៅពូ ឆ្នាំណាអាហ្នឹង?

ឆនៈ ឆ្នាំ៧២ ។

ដានីៈ ហើយកាលហ្នឹងពូនៅក្នុងកងពលអីដែរ?

ឆនៈ ខ្ញុំនៅក្នុងកងពលទីមួយ តែក្នុងវរៈសេនាធំ១៥ ពីដើមវរៈសេនាធំ១៥តែគេសរសេរតែវ១៥ ។

ដានី: កាលហ្នឹងពូនៅក្នុងកងពលទីមួយ ហើយពីណាគេប្រធានកងពលទីមួយ?

ឆន: ឈ្មោះ សឿន តែខ្ញុំអត់ស្គាល់ត្រកូលគាត់ទេ ។

ដានី: ឈ្មោះ សឿន?

ឆន: បាទ! តាសឿនហ្នឹងអ្នកភូមិខត្តរនេះ ។

ដានី: ចុះវរៈសេនាធំ១៥ពីណាគេ?

ឆន: វរៈសេនាធំឈ្មោះ យន ពីមុនគេហៅបង១៨ ។

ដានី: ឈ្មោះ យន ១៨?

ឆន: បាទ!

ដានី: ឈ្មោះ យន ដែលគាត់ធ្វើប្រធានកងពល១៩មុនឌុល សារឿនហ្នឹងមែន?

ឆន: បាទ! យនហ្នឹងឯង តាយន តារឿនគ្នាគេហើយ ។

ដានី: តារឿនគាត់ប្រធានវរៈសេនាធំដែរ?

ឆន: កាលនៅព្រំដែនគាត់ជាសមាជិកកងពល តែគេឲ្យនៅជួរផ្នែកខាងក្រោយ ។

ដានី: ចុះកាលពូនៅវរៈសេនាធំ១៥ហ្នឹង កាលហ្នឹងពូមានតួនាទីអីដែរ?

ឆន: ខ្ញុំកាន់វិទ្យុទាក់ទង ។

ដានី: កាន់វិទ្យុទាក់ទង?

ឆន: បាទ!

ដានី: ពូរៀនយ៉ាងម៉េចអាកាន់វិទ្យុទាក់ទងហ្នឹង?

ឆន: អានេះមិនរៀនអីផងបើនិយាយទៅ អាហ្នឹងតាមស្មារតីដែលអាចធ្វើទៅកើត កាលនៅក្នុងព្រៃខ្ញុំមើលអ្នកកាន់មុនៗម៉ោគេចេះភាសាចេះអង្លេសចេះអីណា៎ ដល់ពេលម៉ោដល់ខ្ញុំអត់ចេះអីផងប៉ុន្តែរៀនបាន៣ អក្ខរាវិរុទ្ធ បកជាសារ និយាយជាចំនុចៗ និយាយជាលេខ មិនមែនបាននិយាយមាត់ទទេដូចយើងនិយាយទៅនេះទៅនោះអីទេ ។

ដានី: បាទ! កាលហ្នឹងកងពលទីមួយស្ថិតនៅភូមិភាគអីដែរ?

ឆន: កាលហ្នឹងវាចំនុះឲ្យភូមិភាគនារតីទាំងអស់ ទាំងកំពត តាកែវ កំពង់សិលា កោះកុង កំពង់ឆ្នាំង កំពង់ស្ពឺហ្នឹង រួមម៉ោគឺភូមិភាគនារតី ហើយបែងចែកនេះគឺនៅឆ្នាំ៧៦,៧៧អីទេ អាហ្នឹងចេញពីភូមិភាគទេណា៎ មានខត្ត មានបច្ចឹម មានពាយ័ព្យហ្នឹងកាលពីមុនវាមានតែប៉ុន្មានហើយទេ ហើយដូចខ្ញុំនៅអមលាំងអីហ្នឹងសុទ្ធតែនារតីហើយ ។

ដានី: ភូមិភាគនារតី?

ឆន: តែបើតាមសព្វថ្ងៃនេះគឺវាភូមិភាគបច្ចឹមហើយ ។

ដានី: ពូនៅវ៉ៃរហូតដល់ពេលណា ខាងត្បូងតូច ត្រពាំងពោ?

ឆន: វ៉ៃរហូតដល់ឆ្នាំ៧៥ ។

ដានី: ឆ្នាំ៧៥ ?

ឆន: បាទ! អាហ្នឹងចូលទៅតាមដូហ្នឹងទៅគឺវត្តពោ ។

ដានី: ពូកាន់វិទ្យុទាក់ទងរហូតដល់ឆ្នាំ៧៥ ?

ឆន: ខ្ញុំទៅដល់ព្រំដែនរហូតដល់សព្វថ្ងៃ ព្រោះអ្នកដែលកាន់ផ្សេងទៀតទៅច្រើនតែពេលដែលមានអាសន្ន ដូចថាពេលគេព័ទ្ធវ៉ៃអញ្ចឹងទៅគ្នាវាអត់មានស្មារតីនិយាយ ដល់ពេលអញ្ចឹងទៅឆ្លើយឲ្យគេអត់រួច គេអត់ទទួលបាន ហើយខ្ញុំគេអត់ដកទៅណាទេ តែមុនហ្នឹងនេះវាឆ្អែតដែរគេយករុញចូលទៅដល់ ពូស្គាល់វត្តព្រះពុទ្ធធំនៅស្វាយរៀងទេ?

ដានី: អត់ផង ។

ឆន: ខាងជើងខាងកើយប្រសូត្ររាងប្រឆាកជាមួយស្រុកព្រះតូច ។

ដានី: ចុះតា សឿងហ្នឹងគាត់កងពលទីមួយរហូតដល់បែក៧៥ ដែរ?

ឆន: ពេលគេរៀបរយហើយខ្ញុំមិនដឹងទេ គេដកខ្ញុំម៉ោនៅវិញហើយគេដកតា សឿងហ្នឹងចេញ ។

ដានី: អញ្ចឹងនៅមួយជួរខាងកំពង់ស្ពឺហ្នឹងមានប៉ុន្មានកងពល?

ឆន: អញ្ចេះកងពលវាមានឈ្លប មានឈ្លបឃុំ ឈ្លបកងទ័ពស្រុក កងទ័ពតំបន់ ភូមិភាគដែលខ្ញុំនិយាយនេះខ្ញុំនិយាយតែកងទ័ពភាគទេណ៎ា ហើយកងទ័ពភាគហ្នឹងវាមានតែមួយកងពលហ្នឹងទេ ហើយកងពលទីពីរនៅតាកែវ ភូមិភាគនារតីដូចគ្នាតែគេនៅតាកែវ ។

ដានី: បាទ!

ឆន: ខ្ញុំនៅមួយជួរពីស្រុកកគោ ទៅដល់កំពង់ស្ពឺ ។

ដានី: ស្រុកកគោ ខេត្តអី?

ឆន: ខេត្តពោធិ៍សាត់ ។

ដានី: បាទ!

ឆន: ខ្ញុំនៅខាងលិចបរិបូរណ៍ ម៉ាជួរត្រពាំងចាន់ ត្រពាំងព្រាម ស្វាយអាត់ស្វាយអីហ្នឹង ។

ដានី: ត្រពាំងចាន់ស្វាយអាត់?

ឆន: ស្រុកបរិបូរណ៍ ។

ដានី: អញ្ចឹងដល់ពេលបែកភ្នំពេញឆ្នាំ៧៥ ហ្នឹងពូទៅណា?

ឆនៈ អត់ទេគេយកម៉ោដាក់នៅវត្ត ។

ដានីៈ ដាក់វត្តណា?

ឆនៈ ដាក់នៅវត្តកន្ទែងកែងហ្នឹង ។

ដានីៈ វត្តកន្ទែងកែង?

ឆនៈ បន្ទាយលង្វែក ។

ដានីៈ បន្ទាយលង្វែក?

ឆនៈ បន្ទាយលង្វែកវត្តកន្ទែងកែង

ដានីៈ កងពលលោកពូម៉ោវត្តកន្ទែងកែងហ្នឹងវិញ?

ឆនៈ អត់ទេវរៈសេនាធំ វរៈសេនាធំហ្នឹងដល់ពេលកងពលវារៀបរយហើយគេបញ្ជូនខ្ញុំទៅស្រុកព្រៃនុប ។

ដានីៈ ស្រុកព្រៃនុបខាងខេត្តកំពត?

ឆនៈ តែឥលូវហ្នឹងវាចូលទៅក្នុងខេត្តកំពង់សោមវិញហើយ ។

ដានីៈ អញ្ចឹងមុនដំបូងគេបញ្ជូនទៅវត្តកន្ទែងកែងនៅកងពលទីមួយហ្នឹង?

ឆនៈ បាទ! កងពលទីមួយឲ្យទៅនៅហ្នឹងធ្វើស្រែ ។

ដានីៈ ធ្វើស្រែ?

ឆនៈ ធ្វើស្រែហើយគេបញ្ជូនម៉ោ ។

ដានីៈ ចុះកងពលហ្នឹងគ្នាច្រើនទេ?

ឆនៈ ច្រើន មានវរៈសេនាធំ១៥ ។១៦,១៧ហើយមាន៣វរៈសេនាធំពេញ ។

ដានីៈ បាទ!

ឆនៈ ហើយវាមានកងអន្តរាគមន៍ ។

ដានីៈ ហើយអញ្ចឹងតា សឿង ហ្នឹងពេលដែលម៉ោដល់គាត់ផ្លាស់ចេញ?

ឆនៈ ពេលហ្នឹងគាត់អស់... ។

ដានីៈ ផ្លាស់ហ្នឹងពីណាគេម៉ោទទួលថ្មី?

ឆនៈ ដូចជាបងសេង បងសេងហ្នឹងគេដកពីវរៈសេនាធំម៉ោ កាលហ្នឹងមិនដឹងឡើងបានប៉ុន្មានទេព្រោះវាស្លាប់ច្រើន ។

ដានីៈ ចុះសារឿន?

ឆនៈ បងសារឿនហ្នឹងខ្ញុំមិនស្គាល់គាត់ទេ គ្រាន់តែបានជួបគាត់ ។

ដានី៖ ជួបគាត់នៅក្រចេះ?

ឆនៈ បាទ!

ដានី៖ កាលហ្នឹងគាត់នៅកងពលទីមួយដែរមែន?

ឆនៈ អត់ទេ គាត់នៅខាងភូមិភាគពិសេស ។

ដានី៖ អញ្ចឹងពេលម៉ោនៅវត្តកន្ទែងកែងហ្នឹងបានប៉ុន្មាន?

ឆនៈ បានម៉ាធ្វើស្រែហើយ ។

ដានី៖ ធ្វើស្រែហើយបានទៅព្រៃនោះ?

ឆនៈ បាទ!

ដានី៖ ធ្វើអីនៅព្រៃនោះ?

ឆនៈ គេឲ្យការពារ ។

ដានី៖ គេឲ្យការពារដែនទឹក?

ឆនៈ បាទ!

ដានី៖ អាហ្នឹងកងពលអីគេអាហ្នឹង?

ឆនៈ នៅហ្នឹងកងពលទីមួយដដែល គ្រាន់តែគេផ្លាស់ប្តូរមនុស្សវរៈសេនាធំឡើងធំអញ្ចឹងទៅ ។

ដានី៖ ផ្លាស់ប្តូរពីណាទៅណា?

ឆនៈ តែវរៈសេនាធំនោះឡើងបានមួយភ្លែតអញ្ចឹងអស់សុពល ដូចតាលិន ពីដើមគេហៅតែតាលិនៗ បើខ្មែរក្រហមគេហៅតែបង ។

ដានី៖ អញ្ចឹងទៅព្រៃនុបហ្នឹងទៅខាងការពារដើងទឹក?

ឆនៈ បាទ!

ដានី៖ ចុះមានកងពលអីផ្សេងទេ?

ឆនៈ ខាងកំពង់សោមខាងកងពលគេផ្សេង?

ដានី៖ ពីណាគេ?

ឆនៈ ខ្ញុំអត់ស្គាល់ទេ អាហ្នឹងវរៈសេនាធំខាងតាសេងហ្នឹង ។

ដានី៖ តាសេង?

ឆនៈ បាទ! គាត់ការពារហ្នឹងឯង កាលឆ្នាំ៧៦ដូចមានគេវៃគ្នាម្តង វៃនៅកោះហើយតានេះបានគាត់ទៅជួប ។

ដានី៖ ទៅជួបអីគេ?

ឆនៈ ជួបខុបត្តិហេតុដែលកើតឡើងនៅកោះនោះ វ៉ៃគ្នានៅកោះនោះ ។

ដានីៈ ប៉ុន្តែកងទ័ពគាត់មិនមែនអ្នកទៅវ៉ៃទេ?

ឆនៈ គាត់ខ្លួនគាត់អីនៅហ្នឹងទាំងអស់ ។

ដានីៈ គាត់នៅកន្លែងវ៉ៃដែរ?

ឆនៈ បាទ!

ដានីៈ កន្លែងកាប៉ាល់ម៉ាយ៉ាកេសហ្នឹង?

ឆនៈ ហ្នឹងអើយ តាហ្នឹងគាត់ឆ្លងដែនការរបស់គាត់ផុតហើយតែនៅកងទ័ពរបស់គាត់នៅ ហើយអាមេរិចគេចាប់បាន ។

ដានីៈ អាមេរិចចាប់បានគេធ្វើយ៉ាងម៉េចទៅ?

ឆនៈ ប្រហែលជាគេប្រគល់ឲ្យវិញមិនដឹង កាលហ្នឹងស្ងាត់ខ្ញុំវាមិនសូវយល់ដល់ទេការងារបក្សហ្នឹង ។

ដានីៈ ចុះតាមុត គាត់ប្រធានកងពល១៦៤?

ឆនៈ ត្រូវហើយតាមុតហ្នឹងឯង ។

ដានីៈ តាមុតហ្នឹងគាត់នៅណា?

ឆនៈ សព្វថ្ងៃនៅកោះកុង ។

ដានីៈ តែកាលពីសម័យពូនៅព្រែកនុបគាត់នៅណា?

ឆនៈ គាត់នៅព្រំដែន តាមុតហ្នឹងគេធំយូហើយ ។

ដានីៈ គេធំយូហើយ?

ឆនៈ បាទ!

ដានីៈ ចុះពូទៅនៅព្រែកនុបហ្នឹងនៅបានរយៈពេលប៉ុន្មាន?

ឆនៈ ខ្ញុំនៅចុង៧៥ដល់ចុង៧៦គេបញ្ជូនខ្ញុំទៅស្វាយរៀង ។

ដានីៈ ៧៦គេបញ្ជូនពូទៅស្វាយរៀង?

ឆនៈ អាហ្នឹង៧៦ចូល៧៧ហើយ ព្រោះគេវ៉ៃគ្នា៧៦ហើយ ដល់ពួកគេវ៉ៃទៅបានទទួលជោគជ័យថ្ងៃ៦មករា ។

ដានីៈ កាលហ្នឹងជោគជ័យថ្ងៃ៦មករាយ៉ាងម៉េច?

ឆនៈ ជោគជ័យដែលគេដេញយួនចេញបានប៉ុន្មានខេត្តនោះ ។

ដានីៈ អ៎យើងវ៉ៃបានហ្នឹងមែន?

ឆនៈ បាទ!

ដានី៖ កាលហ្នឹងគេផ្លាស់ពូទៅខាងស្វាយរៀង?

ឆនៈ គេឲ្យទៅស្វាយរៀង ។

ដានី៖ កងពលទីមួយទាំងអស់?

ឆនៈ កងពលទីមួយតែពេលទៅដល់នោះគេដូរលេខ គេមានលេខមជ្ឈិម ហើយយើងលេខភូមិភាគ ។

ដានី៖ អាហ្នឹងម៉េចវិញ?

ឆនៈ កងទ័ពមជ្ឈិមមានន័យថាទទួលបញ្ជាពីស៊ុន សេន ។

ដានី៖ ស៊ុន សេន?

ឆនៈ បាទ!

ដានី៖ ស៊ុន សេនកាលហ្នឹងគាត់ជាអីគេ?

ឆនៈ គាត់ជាអគ្គបញ្ជាការក្រសួងការពារជាតិ ។

ដានី៖ ហើយកាលហ្នឹងទៅស្វាយរៀងកងពលពូទៅជាកងពលលេខប៉ុន្មាន?

ឆនៈ កាលនៅកងពលតូចលេខ៣៨០ ។

ដានី៖ ៣៨០?

ឆនៈ បាទ!

ដានី៖ នៅម្តុំណា?

ឆនៈ នៅខាងជើងស្រុកប្រសូត្រហ្នឹង នៅជិតវត្តខ្នាយ ។

ដានី៖ កងពលនៅហ្នឹងទាំងអស់?

ឆនៈ បាទ! នៅកណ្តាលវាលហ្នឹង ។

ដានី៖ នៅកណ្តាលវាល?

ឆនៈ ហ្នឹងអើយវាលកន្ទ្រែងស្លឹកគ្រោតហ្នឹង ដេរស្លឹកគ្រោតដេរអីទៅ តែស្លាប់ច្រើនណាស់ ។

ដានី៖ ស្លាប់ច្រើន?

ឆនៈ បាទ!

ដានី៖ កាលហ្នឹងពូមានតួនាទីទេ?

ឆនៈ អ្នកកាន់វិទ្យុដដែលហ្នឹង ។

ដានី៖ កាន់វិទ្យុហ្នឹងមានសិទ្ធស្មើរសាណៈដែរ?

ឆនៈ អត់មានទេ សម័យនោះវាមិនដែលឲ្យមានស័ក្តមានអីផង ។

ដានី៖ ប៉ុន្តែយើងកាន់វិទ្យុហ្នឹងនៅក្នុងរបស់កងពលហ្នុង?

ឆនៈ	របស់កងពលដែរតែរបស់កងពលប្រចាំកងពលដូរមុខ នៅក្រោយគេបានមួយថ្ងៃ ។

ដានីៈ	ចុះទៅដល់នោះប្រធានកងពលពីណាគេ?

ឆនៈ	ប្រធានកងពលឈ្មោះធី ។

ដានីៈ	ធីហ៊្វីងនៅណាទៅ?

ឆនៈ	ធីហ៊្វីងមានស្រុកកំណើតនៅភូមិរលាំងថ្មើម ឃុំផមុខ ស្រុកផ្គង ខេត្តកំពង់ស្ពឺ ។

ដានីៈ	ធីហ៊្វីងគាត់ប្រធានកងពល?

ឆនៈ	បាទ!

ដានីៈ	ចុះគាត់វ៉ៃចូលទៅសម្រួលពីណាគេដែរ?

ឆនៈ	អត់ដឹងទេខ្ញុំនៅក្រៅ ។

ដានីៈ	ចុះពូបានចូលទៅដីយួនដែរ?

ឆនៈ	បាទ! គេរើសតាមវរៈសេនាធំ ម៉ាវរៈសេនាធំហ៊្វីងវាមាន៧០ ហើយគេរៀបចំព្រោះអាហ៊្វីងជាកម្លាំងស្នូល ហើយពួកខ្ញុំនៅក្រោយ តាហ៊្វីងគាត់ដឹងច្រើនព្រោះគាត់កងពល គាត់វរៈសេនាធំគាត់ដឹងច្រើនហើយ ពេលគេហៅគាត់ទៅប្រជុំទៅរៀនទៅសូត្រអី ហើយបើពួកខ្ញុំអត់ដឹងអីទេ អត់ដឹងថាគេសម្លាប់ម៉ែឪផង ។

ដានីៈ	ពូដែលបានម៉ោលេងផ្ទះទេ?

ឆនៈ	អត់ទេ ។

ដានីៈ	ផ្ញើកង់ទ័ពអត់ដែលបានម៉ោលេងទេ?

ឆនៈ	អត់ទេ ព្រោះនៅនោះមានច្បាប់មានអីរបស់គេ ។

ដានីៈ	ចុះហូបចុកបានគ្រប់គ្រាន់ទេកង់ទ័ព?

ឆនៈ	ពីរឆ្នាំបើយើងរំដោះបានហើយអាហ៊្វីងបានគ្រប់គ្រាន់ ប៉ុន្តែបើមើលឃើញប្រជាពលរដ្ឋអត់បាយពួកសហករណ៍ផ្ញើសកម្មភាពមិនឲ្យបាយឲ្យអីអញ្ចឹង យើងទៅនៅតាមមូលដ្ឋានដឹងហើយពួកវាចេះតែបង្កើតរបបមួយជូនកាលវាឲ្យមួយថ្ងៃបីពេល ហើយបើពួកនោះវាអត់ឲ្យ វាឲ្យមួយថ្ងៃមួយកំប៉ុងកន្ទះ ។

ដានីៈ	គេឲ្យមួយថ្ងៃមួយកំប៉ុងកន្ទះ?

ឆនៈ	វេទនាណាស់ក្របខណ្ឌរបស់គេហ៊្វីង ប៉ុន្តែខ្ញុំដូចថាទៅមិនដឹងទៅណាម៉ោណា និយាយរួមភ័យទៅកាលដែលធំដឹងក្តីឡើងមិនទាន់ដឹងថាពិភពលោកមានអីខ្លះនោះទេ ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថាមានប្រទេសជិតខាងមានមនុស្សមានអី មិនដូចគេសព្វថ្ងៃគេកើតម៉ោឲ្យដឹងភ្លាមៗនោះទេ ។

ដានីៈ អញ្ចឹងពូធ្លាប់ទៅក្រចេះដែរ?

ឆនៈ ក្រចេះម្ដាយធំនៅនោះ ស្រុកដែលយើងទៅច្បាំងមែន?

ដានីៈ បាទ!

ឆនៈ ទៅច្បាំងខ្ញុំទៅបានតែម៉ាកងជំនួយកាលដែលគេដកទៅខាងហ្នឹង កងទ័ពវៀតណាមវាំបុកស្រួចដល់ពេលអញ្ចឹងគេដកអន្តរាគមន៍ហ្នឹងទៅ ដល់ពេលដកអន្តរាគមន៍គេត្រូវយកវិទ្យុទាក់ទងពួកខ្ញុំហ្នឹងទៅប្រើប្រាស់ ខ្ញុំទៅអត់បានប៉ុន្មានទេ គ្រាន់តែកងពលទៅដល់ព្រឹបវៀតណាមមើលទៅសកម្មភាពវាច្បាំងដឹងតែពួកហ្នឹងខ្លាំងហើយអញ្ចឹងវាចាប់ផ្ដើមដកទៅវិញហើយ ហើយពួកខ្ញុំក៏លប់ម៉ោវិញម៉ោ ។

ដានីៈ កាលហ្នឹងនៅក្រចេះតាសារឿនគាត់នៅហ្នឹង?

ឆនៈ បាទ! នៅ០៥ ។

ដានីៈ កាលហ្នឹងកងពលអីគេ?

ឆនៈ កងពល៣០១ ។

ដានីៈ នៅក្រចេះ?

ឆនៈ បាទ!

ដានីៈ នៅក្រចេះហ្នឹងម្ដុំណា?

ឆនៈ ឥលូវនេះមិនដឹងទីណាទីណីទេ ។

ដានីៈ កាលហ្នឹងពូមានចាំថានៅក្រចេះគេហៅអី?

ឆនៈ ក្រចេះដែលខ្ញុំទៅហ្នឹង ទៅហ្នឹងខេត្តហ្នឹងហ្មង ។

ដានីៈ ទៅខេត្តក្រចេះហ្នឹងហ្មង?

ឆនៈ បាទ!

ដានីៈ ទៅជួបតាសារឿននៅក្រចេះហ្នឹងហ្មង?

ឆនៈ ទៅទំនាក់ទំនងជាមួយវរៈសេនាធំប៉ុន្មានទេ ហើយទៅនឹងមិនទាន់បានស្គាល់គ្នាស្រួលបួលផងគេដកម៉ោវិញ ។

ដានីៈ គេដកម៉ោវិញ?

ឆនៈ បាទ!

ដានីៈ ចុះដកម៉ោហ្នឹងដកទៅណាវិញទៅ ហើយឆ្នាំណាដែលទៅក្រចេះហ្នឹង?

ឆនៈ ឆ្នាំដែលទៅក្រចេះគឺដើមឆ្នាំ៧៧ ។

ដានី៖ ដើមឆ្នាំ៧៧?

ឆនៈ បាទ!

ដានី៖ អញ្ចឹងពូទៅស្វាយរៀងហើយមែនទេ?

ឆនៈ ចេញពីហ្នឹងទៅស្វាយរៀង ប៉ុន្តែចេញពីហ្នឹងគេឲ្យនៅស្វាយរៀង ពេលយើងចូលទៅវៃអាដែនការវៃធំម៉ោទូទាំងប្រទេសហ្នឹង ដល់ពេលយើងអត់បានវៃមុនគេវៃបានមុន វៀតណាមរួមជាមួយកងទ័ពរដ្ឋកម្ពុជាហ្នឹងគេវៃមុន ដល់ពេលគេដាក់មុនហ្នឹងបាក់ បាក់ហ្នឹងពួកខ្ញុំត្រូវរបួសហើយក៏គេចវេស ។

ដានី៖ ពូត្រូវរបួសឆ្នាំណា?

ឆនៈ ខ្ញុំត្រូវរបួសឆ្នាំ៧៧ ។

ដានី៖ ឆ្នាំ៧៧ហ្នឹងត្រូវកន្លែងណា?

ឆនៈ ត្រូវជង្គង់ ។

ដានី៖ ហើយអាហ្នឹងត្រូវអីគេ?

ឆនៈ ត្រូវមីន ស្លាប់នោះស្លាប់ កងរបស់ខ្ញុំវៃបីថ្ងៃអស់៧០នាក់ ។

ដានី៖ បីថ្ងៃ៧០នាក់?

ឆនៈ ចុះវាវាលរត់វាមិនរួច ។

ដានី៖ ចុះពេលពូត្រូវរបួសម៉ោដេកពេទ្យ ពូដេកពេទ្យមួយណា?

ឆនៈ ដេកពេទ្យ៦មករា ។

ដានី៖ ពេទ្យ៦មករាជិតវត្តភ្នំហ្នឹង?

ឆនៈ ហ្នឹងអើយមុខវត្តភ្នំហ្នឹងឯង ។

ដានី៖ បាទ!

ឆនៈ ខ្ញុំចេញពីវត្តភ្នំម៉ោគេជីកដាក់រទេះភ្លើងម៉ោគេបាញ់ប្អូនស្រី តែមិនមែនជាប្អូនស្រីបង្កើតទេ ប្អូនស្រីហ្នឹងគ្នាធ្វើពេទ្យគ្រាន់តែរាប់អានទេ សុំរាប់អានទៅ វាហ្នឹងជាអ្នករំដោះខ្ញុំម៉ោបានបាយបានអីហូបនោះ កាលនៅក្នុងពេទ្យហ្នឹងគេឲ្យបាយតែគេលាយជាអំពូលថ្នាំប៉ុនៗនេះគេកិនឲ្យម៉ត់ទៅហើយគេពោយក្នុងបាយឲ្យយើងហូបទៅ ។

ដានី៖ គេពោយធ្វើអីអាហ្នឹង?

ឆនៈ ផែនការគេកាលហ្នឹងខ្ញុំស្តាប់បាន មីប្អូនស្រីហ្នឹងវាខ្សឹបប្រាប់ខ្ញុំថាក្នុងមួយថ្ងៃពេទ្យម្នាក់គេឲ្យសម្លាប់យើងឲ្យបាន១០នាក់ បើមិនសម្លាប់ក៏បានត្រឹមកាត់ជើងកាត់ដៃដែរ ។

ដានី: ម៉េចអញ្ចឹង?

ឆនៈ មិនដឹងដែរ ព្រោះបើតាមយោបល់ខ្ញុំថាប្រហែលជាអ្នកណាក្បត់អ្នកណាមិនដឹង ហើយពេលដែលវាឡូបប្រាប់ខ្ញុំមើលទៅមែន សកម្មភាពឲ្យបាយហូបរៀបចំឲ្យហូបតែពេលយប់ទេ ម៉ោងពីយប់បានបាយហូប?

ដានី: ម៉ោងពីយប់?

ឆនៈ បាទ!

ដានី: ឆ្នាំណា?

ឆនៈ ឆ្នាំដែលខ្ញុំរត់ហ្នឹង គឺឆ្នាំ៧៧ ។

ដានី: រត់ទៅណា?

ឆនៈ ពេលដែលវៀតណាមវ៉ៃចូលម៉ោគ្រឹបម៉ោ កងទ័ពដេញម៉ោហ្នឹងដើមឆ្នាំ៧៨ហ្នឹង ។

ដានី: បាទ! អញ្ចឹងពូត្រូវរបួសឆ្នាំណា?

ឆនៈ ឆ្នាំ៧៨ហ្នឹងឯងគ្រាន់តែថាវាដើមឆ្នាំ ។

ដានី: ពូសម្រាកនៅពេទ្យរយៈពេលប៉ុន្មានទៅ?

ឆនៈ ខ្ញុំដេកយូណាស់ ដេកហើយគេហៅទៅច្បាំងម្តងទៀតណា៎ ។

ដានី: គេហៅទៅច្បាំងនៅកន្លែងណា?

ឆនៈ គេហៅទៅកន្លែងដដែលហ្នឹង ពេលវៀតណាមវ៉ៃចូលដើមឆ្នាំ៧៩ហ្នឹងវ៉ៃចូលថ្ងៃ៧មករាហ្នឹង ហើយខ្ញុំរត់ថ្ងៃហ្នឹងរហូតម៉ោដល់ភ្នំពេញគេដេញបាញ់ ខ្ញុំថាមិនរស់ទេ ហើយអាមួយអ្នកបាញ់ហ្នឹងខ្ញុំស្គាល់វាតែស្គាល់តែមុខទេមិនស្គាល់ឈ្មោះទេ ព្រោះធ្លាប់ប្រយុទ្ធជាមួយគ្នា កាលហ្នឹងគេឃាត់ខ្ញុំកុំរត់តែខ្ញុំថាបងអើយ បើបងមិនឲ្យខ្ញុំរត់នៅនេះបានអ្នកណាមើល ។

ដានី: ពីណាគេបាញ់?

ឆនៈ កងទ័ពរដ្ឋកម្ពុជាហ្នឹងឯង នៅជាមួយតែគ្នាតែមិនដឹងថាអ្នកណាក្បត់អ្នកណា គ្មានអ្នកណាហ៊ានថាអ្នកណានោះទេ គេបាញ់អញ្ចឹងទៅបានដឹងថាគេខ្មាំង កាលមួយវិកហ្នឹង៥០២ជួបជាមួយ១៦៨ក៏មិនបានហើយ១៦៨ជួបជាមួយ៥០២ក៏មិនបាន ម៉ោដល់ព្រំដែនហើយហ្នឹងណា៎ ច្របូកច្របល់ កាលហ្នឹងខ្ញុំបានកាំភ្លើង៩ដើម បាន៩ដើមដល់ពេលម៉ោដល់បងស្រីដែលគាត់ធ្វើពេទ្យឈ្មោះ ឈឿន ខ្ញុំថាបងខ្ញុំអាចនៅជាមួយបងឯងបានទេព្រោះគេម៉ោយកខ្ញុំទៅហើយ ខ្ញុំម៉ោដល់ថ្មគោលជិះរទេះភ្លើងម៉ោដល់ថ្មគោលហ្នឹង ។

ដានី: ពូជិះរទេះភ្លើងពីណាម៉ោ?

ឆនៈ ជិះពីវត្តភ្នំ ។

ដានីៈ ជិះពីវត្តភ្នំ?

ឆនៈ បាទ!

ដានីៈ ក្រែងកាលហ្នឹងពូជាពីរបួសមួយសារហើយពូទៅព្រំដែនមួយសារទៀត?

ឆនៈ ម៉ោហ្នឹង ។

ដានីៈ ម៉ោដេកពេទ្យមួយសារទៀត?

ឆនៈ បាទ! របួសសារហើម៉ោដេកមួយសារទៀត ដល់ពេលម៉ោមួយសារទៀតគេជូនម៉ោ ជិះរទេះភ្លើងម៉ោជាមួយឈឿនហ្នឹង ពេលម៉ោដល់ហ្នឹងតាម៉ុកគាត់ថានាំគ្នាទៅស៊ីបាយទៅនៅពោធិ៍សាត់ទៅ ដល់ពេលទៅដល់ពោធិ៍សាត់គេដាំបាយហើយតែរទេះភ្លើងអត់ឈប់ ។

ដានីៈ ម៉េចបានជារទេះភ្លើងអត់ឈប់?

ឆនៈ មិនដឹងម៉េចមិនហ៊ានថាទេ ក្រែងលោគេមានអំណាចគេ ។

ដានីៈ ពីណាគេមានអំណាច?

ឆនៈ ពួកអាគ្នាឯងនៅហ្នឹងតែមិនដឹងមួយណាបើគ្នាឯងដូចតែគ្នាគេ វាច្របូកច្របល់អញ្ចឹង ។

ដានីៈ អញ្ចឹងតាម៉ុកជិះរទេះភ្លើងម៉ោដែរ?

ឆនៈ អត់ជិះទេ តាម៉ុកគាត់នៅនេះ ។

ដានីៈ អញ្ចឹងម៉េចគាត់ប្រាប់ថាឲ្យម៉ោស៊ីបាយនៅពោធិ៍សាត់?

ឆនៈ គាត់តេអូរទៅ?

ដានីៈ គាត់តេអូរប្រាប់ពីណាគេ?

ឆនៈ តេអូរប្រាប់ពួករទេះភ្លើងហ្នឹង ។

ដានីៈ ដល់ពេលអញ្ចឹងទៅរទេះភ្លើងទៅឈប់នៅណា?

ឆនៈ រទេះភ្លើងម៉ោដល់ហ្នឹងគេអត់ឈប់ឲ្យ ម៉ោឈប់នៅបាត់ដំបង ។

ដានីៈ ម៉ោឈប់នៅបាត់ដំបង?

ឆនៈ ម៉ោនៅអីទួលតាអែក ។

ដានីៈ ទួលតាអែក?

ឆនៈ ម៉ោដល់ទួលតាអែកហ្នឹងម៉ារ៉ូងគ្នាមួយរទេះភ្លើង ពីដើមអត់មានមនុស្សទេ កាលពីមុន មានតែចំការនៅខាងនេះនៅក្រោម ប្រជាជនម៉ោរកកាប់ ទៅកាច់អំពៅគេអស់ អំពៅមួយចំការប្រហែលជា៤ហិចតា ។

ដានី៖ កាប់អស់?

ឆន៖ គ្មានសល់ទេ បើអា២នាក់ដែលរកបាញ់រកអីហ្នឹងគេកាប់ចង់អស់ ហើយខ្ញុំក៏និយាយដែរ ខ្ញុំថាបងបើដាច់បាយពីនោះម៉ោហើយហ្នឹងបងឯងម៉ោបាញ់ចោលថែមធ្វើអី បងឯងឈ្មោះអីបានអីបើគ្នាឃ្លានទៅហើយ បើមិនឃ្លានក៏គ្មានអ្នកណាធ្វើដែរ អានេះដំណាក់កាលខ្ញុំបើដំណាក់បងឯងក៏បងឯងធ្វើដែរ ហើយគាត់ថាបាញ់ចោលឲ្យអស់ៗ ហើយខ្ញុំថាបងបាញ់វាបានតែមួយស្លាប់មានអីអស្ចារ្យ ។

ដានី៖ ហើយម៉េចទៀតទៅពេលដែលម៉ោដល់ទួលតាឯកហ្នឹង?

ឆន៖ មកដល់ទួលតាអែកសកម្មភាពយប់ហ្នឹងគេរកបាញ់រកអីអញ្ចឹង ដល់ពេលព្រឹកឡើងគេបញ្ជូនម៉ោដល់ថ្មគោល ដល់ពេលម៉ោដល់ថ្មគោលគេឈប់នៅហ្នឹងហើយគេឲ្យយកអង្ករដាំបាយ យកអង្ករពីម៉ាស៊ីនស្រូវ ដែលម៉ាស៊ីននៅជាប់ផ្លូវអាម៉ាស៊ីនធំហ្នឹង ។

ដានី៖ បាទ!

ឆន៖ យកម៉ោដាំបាយនៅអាផ្លូវដែលយើងម៉ោពីស្វាយហ្នឹង អាផ្លូវយើងកាច់ទៅបាត់ដំបងនៅកន្លែងស្ពានហ្នឹង តែឥលូវស្ពានហ្នឹងមិនដឹងនៅណាទេ ខ្ញុំដាំបាយឲ្យពេទ្យ កាលហ្នឹងដាំបាយខុសខ្មោចទាំងអស់ខ្មោចទាំងឆ្នាំង ដល់ពេលអញ្ចឹងទៅកុលាបខាងតំបន់ កាលហ្នឹងមានឈ្មោះតាលាវនឹងតាចាយ ។

ដានី៖ តាលាវនឹងតាចាយ?

ឆន៖ តាលាវនឹងតាចាយហ្នឹងគាត់យកឡានទៅយកដល់ថ្មគោល ទៅយកម៉ោហ្នឹងនារីៗគ្នាអត់មានដឹងផ្លូវទៅណាម៉ោណីទេ ហើយក៏ទៅអាផ្លូវទៅលិចទៅរំសាយព្រៃ បើទៅពីនេះទៅបវិលណាំហើយទៅអញ្ចឹងប្រជាជនកាប់សាប់អស់ ។

ដានី៖ ជួបពីណាគេ?

ឆន៖ ប្រជាជន ។

ដានី៖ កាប់សាប់ពីណាគេខ្លះ?

ឆន៖ ច្រើនណាស់ ។

ដានី៖ ម៉េចបានជាប្រជាជនកាប់?

ឆន៖ កាលនោះគេបះបោលអាពួកអាវខ្មៅ ហើយទៅនោះវាសុទ្ធតែខ្មៅទាំងអស់ ហើយចុះមានស្អីមានពណ៌ស្អីមានតែខ្មៅហ្នឹង ដល់ហើយម៉ោខ្ញុំម៉ោដល់រោងម៉ាស៊ីនយើងស្វាយនេះគេឲ្យហូបបាយគ្រាន់តែម៉ោដល់ស្វាយនេះខ្ញុំហូបបាយហើយ គេឡើងមកដល់ផ្សារចំការកូននេះ ម៉ោដល់ចំការ

កូនហ្នឹងយួនម៉ោដល់ហ្នឹងដែរ នាំគ្នារត់ទីណាត់ទីណែងបែកគ្នាអស់ហើយ ហើយខ្ញុំធ្វើដំណើរដើរម៉ោជួបកន្លែងតំបន់ជួបអីហើយចេះតែម៉ោជាមួយគេប៉ុន្តែអត់ស្គាល់ទេណា៎ ព្រោះតែគេថាថ្មពួកៗតែមិនថ្មពួកហ្នឹងមុខម៉េចទេ ពីស្វាយចេកម៉ោថ្មពួកសម្រាកមួយយប់ តែឥលូវយើងទៅអត់បានមួយយប់ផង ។

ដានីៈ ហើយម៉េចទៀតទៅ?

ឆនៈ ដល់ពេលខ្ញុំម៉ោដល់ថ្មពួកនេះ តាចាយនេះឲ្យគេទៅដកកាំភ្លើង ឲ្យកន្លែងតំបន់គាត់ទៅដកកាំភ្លើងពីពួកខ្ញុំ ដល់ហើយមើលទៅមើលមកវាមានច្របូកច្របល់មិនដឹងអ្នកណាមេអ្នកណាកើយ ហើយថាអ៊ុំខ្ញុំរត់តាំងពីណាពីណីម៉ោអ៊ីចឹងម៉ោដកទៀតអត់ឲ្យដកទេ តែដករឿងហើយ កាប់គោមួយក្របីមួយស្លហើយគេឲ្យឡើងទៅហូបលើផ្ទះ គំនិតគេ តែគំនិតខ្ញុំខ្ញុំបានឆ្លងកាត់រួចហើយ ចាញ់បោកអ្នកស្វាយរៀងម្តងហើយ បាញ់ឯវាប់ពួកខ្ញុំឡើងមិនចេះតិច ។

ដានីៈ ចាញ់បោកយើងចេញពីវៃព្រំដែនម៉ោរត់ម៉ោវាដាច់បាយ ដល់ពេលដាច់បាយសហករណ៍គេអបអរអញ្ចេះអញ្ចុះឲ្យទុកកាំភ្លើងក្រាល ស្រវ៉ាតែកាំភ្លើងនឹងកាំបិតចេញអស់ នៅកាំបិតពូថៅវៃគ្នាកាលនោះខ្ញុំដឹងរឿង គ្រាន់តែឃើញភ្នែកពួកនោះញាក់លិចញាក់កើតខ្ញុំដឹងថាពួកនេះអត់ស្រួលទេ ពួកម៉ាកខ្ញុំវាកន្លែងធំ វាថាអូនធ្វើការល្អ ទ្រាបីនៅទាំងបី ចេះសំណាងពួកវាអត់មានបាញ់ខ្ញុំដល់ហើយភូសៗវៃឯវាប់ស្រស់ ហើយគេអីយ៉ា ហើយខ្ញុំក៏អត់មានមាត់អីដែរគ្រាន់តែប្រាប់អាជឹមពួកម៉ាកនៅកន្លែងតូច អាជឹមគេថាម៉េចអា៎ ហើយខ្ញុំថាអ៊ើបើឯងមិនបើកផ្លូវម៉េចបានទៅ ដល់ហើយខ្ញុំចេញពីហ្នឹងទៅពួកកន្លែងតំបន់គេស្កាត់មួយកន្លែងទៀតមានទិន្នាកា៨២ មាន៧៥ ហើយគេគេអូចូលម៉ោចូលលេខខ្ញុំហ្នឹង ហើយខ្ញុំថាអត់ស្រួលគេស្កាត់ផ្លូវ គោះចេញទៅគ្រាន់តែចេញផុតវាត្រៀមតាមដើមត្នោតបាញ់ដាច់ដើមត្នោត អាហ្នឹងរត់មួយសារក្រោយម៉ោដល់ព្រៃឈរខាងកើតអ្នកលឿង វេទនាណាស់ខ្ញុំ ខ្ញុំរត់ម៉ោទម្រាំតែដល់ពេទ្យគេបាញ់នៅអ្នកលឿងហ្នឹងឯង អារបួសហើយគេសែងដាក់ឡានម៉ោពេទ្យបានហើយគេអត់ឲ្យឆ្លងទៀត ។

ឆនៈ ម៉េចអញ្ចឹង?

ដានីៈ ខ្ញុំយល់មិនដល់ទេបើគេធ្វើអញ្ចឹង មិនដឹងថាម៉េច ដល់ពេលខ្ញុំម៉ោដល់ស្រុកថ្មពួកនេះគេដកកាំភ្លើងអញ្ចឹងហើយខ្ញុំហ្នឹងរត់ម៉ោដល់គេឲ្យយកឡានម៉ោទទួលដឹកទៅវត្តកណ្តាល កណ្តាលព្រែកតាយឹង ។

ឆនៈ កណ្តាលកាលហ្នឹងអត់មានអីគេ?

ដានីៈ នៅព្រែកតាយឹងកំពង់ស្ពឺហ្នឹង?

ឆនៈ នេះអាកណ្តាលយើងនេះ កណ្តាលយើងខាងកើតបឹងត្រកួន ។

ដានីៈ អញ្ចឹងពូថាគេកាប់គោកាប់អីឲ្យ?

ឆនៈ កាប់គោហ្នឹងខ្ញុំនិយាយពេលខ្ញុំម៉ោទេ អាហ្នឹងចេញពីព្រំដែនម៉ោទេវគ្គទី២ទេ ។

ដានីៈ បាទ!

ឆនៈ ចេញម៉ោគេទទួលអបអរតែជាល្បិចរបស់គេទេ គេសម្លាប់យើងដើម្បីយកអាវុធ ដល់ពេលម៉ោដល់នេះគេឲ្យខ្ញុំម៉ោដេកជាមួយកងទ័ពគេការពារព្រំដែន ហើយខ្ញុំអត់ទុកចិត្តទេខ្ញុំថាអ្នកណាបាញ់ងាប់ហើយ អង្ករ២៥កំប៉ុងខ្ញុំអត់ហ៊ានស្រាយ បើខ្ញុំនិយាយប្រាប់ក្រោមដើមស្វាយខ្ញុំថាមាសអត់មានតម្លៃ បើខ្ញុំយកមាសខ្វះអីមាសតែខ្ញុំយកទៅណា ។

ដានីៈ មាសនៅណា?

ឆនៈ មាសម៉ោពេញៗឡាននៅភ្នំពេញ លោកក្មួយឯងអត់ដឹងទេមិនមែនឡានអញ្ចឹងទេ សុទ្ធតែអាកង់៦អាស៊ីអាស៊ីសសង់គេនោះណា៎ អា៦០០នោះណា៎ អង្ករទាំងបាវៗហើយមានមាស មានត្រីងៀតទៅ មានស្អីគេត្រៀមណា៎ គេប្រុងរត់តែខ្ញុំមិនដឹងរឿង ពួកម៉ាកខ្ញុំថាម៉េចឯងមិនយកទៅហើយខ្ញុំថាអញមិនយកទេអញសុខចិត្តយកអង្ករវិញ ព្រោះកាលហ្នឹងមាសវាអត់មានតម្លៃ អត់ជឿថាមាសមានតម្លៃនោះទេ ទាំងគេទាំងខ្ញុំអត់មានអ្នកណាកាន់អីម៉ោទេ ហើយពួកម៉ាកខ្ញុំក៏អត់មានអ្នកណាយកអីម៉ោដែរ តែខ្ញុំចេះតែបានរស់ម៉ោ ហើយអ្នកដែលបានស្អីៗម៉ោមិនដែលបានរស់មួយទេ កាលមួយរឹកហ្នឹងចប គេធ្វើចបធ្វើពីមាសហើយគេបញ្ជូនទៅស្រុក ។

ដានីៈ បញ្ជូនមាស?

ឆនៈ អាហ្នឹងរឿងសម្តេចទេខ្ញុំមិនបានយល់ទេ ។

ដានីៈ ចុះពូម៉េចទៅពេលដែលម៉ោដល់ព្រំដែន?

ឆនៈ ម៉ោដល់ព្រំដែនហើយបានគេចងក្រងទៅជួប ជួបតាយន តាយនហ្នឹងគាត់រៀបចំម៉ោពីកើតម៉ោបានម៉ោជួបតានេះ ។

ដានីៈ តាអី?

ឆនៈ តាអត់មានកាណុង

ដានីៈ តាវឿនមែន?

ឆនៈ តាហ្នឹងឈ្មោះតា១០៧ ។

ដានីៈ គាត់ឈ្មោះតា១០៧មែន?

ឆនៈ បាទ! ខ្ញុំមិនដែលហៅតាហៅ១០៧ទេខ្ញុំហៅតែតាអត់កាណុង ។

ដានីៈ តាអត់កាណុង?

ឆនៈ ចុះ១០៧មានអ្នកណាគេបាញ់មានកាណុង ។

ដានីៈ ពូលេងសើចជាមួយគាត់ធម្មតាគាត់អត់មានថាអីទេ?

ឆនៈ អត់ទេ តែឥលូវគាត់ចូលយេស៊ូទៅខ្ញុំអត់សូវហ៊ានលេងសើចជាមួយគាត់ទេព្រោះខ្លាចគាត់ប្រកាន់ ។

ដានីៈ គាត់ប្រកាន់?

ឆនៈ គេចាត់ទុកថាគេអស្ចារ្យព្រោះគេធ្លាប់ដឹកនាំខ្មែរក្រហមណា៎ ហើយបើតាមខ្ញុំមើលទៅគាត់គ្រប់គ្រងវាអត់តាមសភាពការណ៍ ។

ដានីៈ ដល់ពេលពូម៉ោដល់ព្រំដែនដំបូងរៀបចំយ៉ាងម៉េចទៅ ខ្ញុំចង់ឲ្យពូជួយរៀបរាប់បន្តិច ។

ឆនៈ ពីដំបូង?

ដានីៈ ការកកើតដំបូង?

ឆនៈ ដំបូងចូលផ្ទះប្រជាពលរដ្ឋ ហើយរត់ចោលស្រុកអស់អត់មានអ្នកណាហ៊ាននៅទេព្រោះគេខ្លាចពួកអាអាវខ្មៅ តែដឹងយ៉ាងម៉េចទេ ដំហានដំបូងកាលហ្នឹងតាមជួរព្រំដែននេះនិយាយពីប្រជាជនរត់ពួន ប្រជាជនរត់ពួនថៃក៏ម៉ោ ប្រជាជនយើងក៏ទៅ អញ្ចឹងដល់យើងរៀបចំកងទ័ពទៅយើងទាក់នៅហ្នឹងទៅដូចថាចាប់ថៃបានអញ្ចឹងយើងអត់មានយកអីទេ ឥវ៉ាន់ក៏អត់មានយកដែរ ហើយស្ត្រីក៏យើងអត់មានយកដែរ អាហ្នឹងយើងដាច់បាយអញ្ចឹងយើងសុំអង្ករ សុំអង្ករឥវ៉ាន់ដែលគាត់ស្ពាយទាំងប៉ុន្មានហ្នឹងឲ្យគាត់យកទៅវិញ យើងយកតែអង្ករទេ ម្នាក់មួយតៅៗម៉ោហើយរៀបចំកងទ័ពម៉ោ វេទនាណាស់ពី៧៩ថាមិនរស់ផង ដូចគេស្រែកថាពួកខ្មែរក្រហមស៊ីស្លឹកថ្មីងហ្នឹងត្រូវហើយអត់ខុសទេ ។

ដានីៈ ចុះម៉ោដល់ព្រំដែនពូជួបដំបូងនៅម្តុំណា?

ឆនៈ នៅភ្នំឆ័ត្រ ។

ដានីៈ កាលហ្នឹងជួបពីណាខ្លះទៅនៅភ្នំឆ័ត្រ?

ឆនៈ ខ្ញុំជួបបងឌុល សារឿន តារឿន តាយន ហើយបងឌុល សារឿនកាលហ្នឹងគាត់អត់ទាន់បានឡើងកងពលទេ ។

ដានីៈ ហើយពីណាកងពល?

ឆនៈ កងពលបងយននេះ ។

ដានីៈ បាទ!

ឆនៈ បងយន បងវឿន បងវឿនគាត់អត់ទាន់មានដំណែងទេ ។

ដានីៈ បងយនហើយគាវឿន?

ឆនៈ បាទ!

ដានីៈ ឈ្មោះស្អី វឿន?

ឆនៈ មាស សាវឿន ។

ដានីៈ ហើយជួបគាត់នៅភ្នំឆ័ត្រហើយយ៉ាងម៉េចទៀតទៅ?

ឆនៈ ពេលជួបហើយគេរៀបចំទៅ ហើយគេស្គាល់កងទ័ពចាស់ដែលរត់ម៉ោជាមួយកងទ័ពនៅព្រំដែនហ្នឹង ហើយពួកព្រំដែនគេស្គាល់សមរភូមិគេនាំដើរទៅ ហើយដើរជួបប្រជាជនអ្នកខ្លះបង្ហាញខ្លួនអ្នកខ្លះត្រៀម បើមិនអញ្ចឹងចាប់គាត់អត់បានទេ អត់ឲ្យជួបទៀត ក្រោយពេលពួកខ្ញុំធ្វើនយោបាយបានម៉ោ បានសារ៉ុង បានប៊ីចេង បានម្រិច ជួបម្ដងអញ្ចឹងឲ្យសារ៉ុងឲ្យអី ទៅវិញគាត់ខ្សឹបប្រាប់គ្នាគាត់ថាទុកអង្ករទុកអីអញ្ចឹងទៅ អាហ្នឹងដូចដូរគ្នាទាំ ដល់ពេលអញ្ចឹងទៅទំនាក់ទំនងយើងបានចាត់បណ្ដាញនៅតាមភូមិមួយៗហ្នឹង ។

ដានីៈ យើងទាក់ទងម៉េចនៅខាងម៉ាឡៃ ខាងយើងនេះហ្នឹងយ៉ាងម៉េច?

ឆនៈ ទូរលេខយើងហ្នឹង យើងធ្វើសារ ឧទាហរណ៍យើងសរសេរថាឥលូវសុំជំនួយ អាហ្នឹងឧទាហរណ៍ទេណា ។

ដានីៈ បាទ!

ឆនៈ យកមកឲ្យពួកបកប្រែ យកមកដល់គេបកប្រែទៅគេដាក់តែលេខទេ ហើយទៅគេយកទៅឲ្យអ្នកកាន់ទូរលេខនោះគេចុច អាហ្នឹងដឹងរឿងទៅទទួលណាអីណា ។

ដានីៈ អញ្ចឹងម៉ោដល់ព្រំដែនភ្នំឆ័ត្រនោះគេរៀបចំកងពលហើយ?

ឆនៈ កងពល៥១៩ ។

ដានីៈ ៥១៩ហ្នឹងពីណាគេអ្នករៀប ដាក់លេខដាក់អីហ្នឹង?

ឆនៈ ខាងលើ ។

ដានីៈ ខាងលើណាអ្នករៀប?

ឆនៈ ខាងប៉ុល ពត ។

ដានីៈ ខាងប៉ុល ពត?

ឆនៈ បាត! ព្រោះយើងរត់យើងដាច់គ្នាទាំងមនុស្ស ទូរលេខវានៅតែយក ។

ដានីៈ កាលហ្នឹងពូមានជួបតាចៀមអីនៅភ្នំឆ័ត្រដែរទេ?

ឆនៈ	តាចៀមគាត់នៅខាងត្បូង ។

ដានីៈ	នៅខាងត្បូង?

ឆនៈ	បើនិយាយថាប៉ោយប៉ែតទៅត្បូងគេហៅថាស៊ីសុផុនខាងត្បូង ហើយបើខាងជើងហៅថាស៊ីសុផុនខាងជើង មាន៥១៩ មាន៩៥០ ។

ដានីៈ	បាទ!

ឆនៈ	ហើយកន្លែងតាកនមាន៣២ ។

ដានីៈ	បាទ!

ឆនៈ	ហើយតំបន់តាកនមាន៣២រ តាកនហ្នឹងឥលូវមិនដឹងម៉េចហើយទេ ចាស់ហើយតាមមើល ។

ដានីៈ	ពូស្គាល់គាត់ដែរ?

ឆនៈ	គាត់កាលសម័យនោះគាត់នៅខាងពិធីការ គាត់នៅខាងទទួលភ្ញៀវ ។

ដានីៈ	ព្រលានសៀមរាប?

ឆនៈ	បាទ!

ដានីៈ	ជាមួយតាកនមែន?

ឆនៈ	នី កន ។

ដានីៈ	ចុះតាចៀម?

ឆនៈ	អត់ទេ ។

ដានីៈ	ចុះអៀង សារីដែលជួបគាត់ទេ?

ឆនៈ	អៀង សារីជួបពេលដែលខ្ញុំត្រូវរបួសទេ ហើយខ្ញុំម៉ោនេះត្រូវគ្រាប់មួយសារទៀត អាផុតពីអានេះទៅត្រូវចំកណ្ដាលទ្រូង ត្រូវក្បាល ត្រូវគូទ ហើយទៅដេកកាលហ្នឹងវិជ្ជបណ្ឌិតមានជួន ជឿន ដើងខ្ញុំនេះទៅជួន ជឿនទេ បើសិនទៅបារាំងកាត់បាត់ហើយ ។

ដានីៈ	ជួន ជឿនគាត់ពូកែមែន?

ឆនៈ	គាត់ព្យាបាលនេះណាស់ មុននឹងស្លាប់មុននឹងនេះហ្នឹងគាត់ព្យាបាលទាល់តែអស់លទ្ធភាពគាត់ ប៉ុន្តែភាគច្រើនមិនសូវខូចបស់គាត់ផង ខ្លាចតែខ្ទេចវល់ ខ្ទេចវល់ជាច់សរសៃឈាមវល់អីអាហ្នឹងបានយ៉ាប់ បើថានៅធម្មតាឆ្អឹងអត់បាក់អាហ្នឹងអត់អីទេ គាត់ថាអត់មានបង្កើតបានមួយថ្ងៃយកទៅប្រាំងបាននោះទេ បើកាត់ជើងកាត់បាត់ហើយ តាហ្នឹងគាត់ត្រូវជាមួយខ្ញុំព្រោះខ្ញុំអ្នកមាត់ដែរ មាុំងទៅមាុំងម៉ោ គាត់ចូលចិត្តអ្នកមាុំងទៅមាុំងម៉ោ ។

ដានីៈ	ចុះពេលពូនៅកងពល៥១៩ហ្នឹង តាំងពីដើមម៉ោពូនៅកងពល៥១៩ហ្នឹងរហូត?

ឆន៖ បាទ!

ដានី៖ ទីតាំងកងពល៥១៩ នៅណាដែរ?

ឆន៖ ទីកន្លែងមេកងពលនៅភ្នំឆ័ត្រ ។

ដានី៖ នៅភ្នំឆ័ត្រ?

ឆន៖ បាទ! ហើយមូលដ្ឋានដែលគេតស៊ូមានប្រជាពលរដ្ឋគេនៅគឺខ្វងហាត ។

ដានី៖ ខ្វងហាត?

ឆន៖ បាទ!

ដានី៖ ហើយចុះប្រពន្ធពូអីនៅណាទៅ?

ឆន៖ គាត់នៅខ្វងហាត ។

ដានី៖ ខ្វងហាត?

ឆន៖ បាទ! ដែលគេហៅថាជំរុំ៨៥ ។

ដានី៖ អ៎ជំរុំ៨៥?

ឆន៖ បាទ! កាលហ្នឹងកងទ័ពយើងនៅហ្នឹងបង្កើតការរើជម្រុកចូលហើយគេអនុវត្តន៍ អាហ្នឹងដូចគេហៅទម្លាក់មុងទាំងមូស ភាសាសង្រ្គាមគេហៅថាទម្លាក់មុងទាំងមូស អញ្ចឹងក្រោយពេលដែលបងសារៀនគាត់ដឹងហើយក៏គាត់បន្ថយចំបាំងហ្នឹងទៅដើម្បីទប់ទល់គ្នា ពួកកងទ័ពវៀតណាមម៉ោគាត់រើតែប៉ារ៉ា ។

ដានី៖ រើតែប៉ារ៉ា?

ឆន៖ ខ្មែរក្រហមវាយ៉ាប់តែរឿងគ្រោះថ្នាក់ច្រើន ហើយអត់បានអីទៀត បើរើពួកប៉ារ៉ាបាន ។

ដានី៖ បានអីគេរើប៉ារ៉ា?

ឆន៖ បានរបស់របរហូបចុក ព្រោះពួកហ្នឹងវាសំបូរហូបណាស់ព្រោះវានៅជាប់ជាមួយពួកអន្តរជាតិយូអិនអា គេនៅបានអញ្ចឹងទៅចេះតែបានហើយ ។

ដានី៖ ចេះតែបានហើយហូបចុកអីហ្នឹង?

ឆន៖ បានហូប ហើយពួកខ្ញុំក៏អត់ខ្វះដែរប៉ុន្តែគ្រាន់តែថាពួកគេអត់អស់ចិត្តគេ កងទ័ពបើសិនជាឡើងម៉ោអញ្ចឹងមេកងទ័ពម៉ោមីអីទាំងកេះៗ អ្នកណាហូបមីហូបទៅ អ្នកណាហូបបាយហូបទៅ ។

ដានី៖ អញ្ចឹងកាលហ្នឹងគណៈកងពលមាន..?

ឆន៖ មានបងយន ។

ដានី៖ មានបងយន?

ឆន:	មានបងសារឿន មានបងរឿន ។

ដានី:	ចុះកាលហ្នឹងពូមានតួនាទីអីគេដែរ?

ឆន:	ខ្ញុំអត់ទេ កាន់គេអូរហូត ។

ដានី:	កាន់គេអូរបស់កងពលហ្នឹងមែន?

ឆន:	ខ្ញុំកាន់គេអូក្រោយម៉ោគេដកខ្ញុំឲ្យម៉ោនៅខាងក្រោយ ម៉ោនៅក្រោយគេឲ្យម៉ោនៅជាមួយតារៀម តារៀមហ្នឹងគាត់ពីដើមជាចៅហ្វាយស្រុកថ្មពួក ។

ដានី:	ពីដើមហ្នឹងពីជំនាន់ណា?

ឆន:	ពីជំនាន់ខ្មែរក្រហមហ្នឹង ។

ដានី:	ជំនាន់៣ឆ្នាំ?

ឆន:	បាទ!

ដានី:	គាត់គណៈស្រុកថ្មពួកមែន?

ឆន:	បាទ!

ដានី:	ឈ្មោះតារៀម?

ឆន:	បាទ!

ដានី:	ចុះឥលូវគាត់ទៅណាហើយ?

ឆន:	ឥលូវនៅម៉ាជួរភ្នំព្រឹក ។

ដានី:	នៅភ្នំព្រឹក?

ឆន:	បាទ!

ដានី:	គាត់ឈ្មោះតារៀម?

ឆន:	បាទ!

ដានី:	ប្រពន្ធគាត់ឈ្មោះអី?

ឆន:	ឈ្មោះ សុខា ។

ដានី:	នៅភ្នំព្រឹក?

ឆន:	បាទនៅភ្នំព្រឹក ។

ដានី:	ផ្ទះគាត់នៅភ្នំព្រឹកងហ្នង?

ឆន:	បាទ! កាលពីដើមផ្ទះគាត់នៅផ្ទះជាមួយពួកខ្ញុំដែរហ្នឹង ដល់ឥលូចនេះដោយសារតែការផ្អែកដំឡើងបុនស័ក្តដល់ពេលអញ្ចឹងគេប្រុងធ្វើឃាតធ្វើអីខ្វះហ្នឹង ។

ដានី៖ គេប្រុងធ្វើបាបគាត់មែន?

ឆន៖ បាទ! គាត់នៅមិនបានដល់សភាពការណ៍វាស្រួលគាត់ទៅហ្នុងទៅ ។

ដានី៖ គាត់ទៅនោះវិញ?

ឆន៖ បាទ! គាត់អ្នកតាកែវ ។

ដានី៖ តាវៀមអ្នកតាកែវ?

ឆន៖ បាទ!

ដានី៖ អញ្ចឹងលោកពូក្រោយម៉ោទៅខាងក្រោយវិញ?

ឆន៖ បាទ!

ដានី៖ ទៅខាងក្រោយធ្វើអីគេវិញ?

ឆន៖ ទៅខាងក្រោយអត់មានអីទេ ខ្ញុំម៉ោស្តាយតែគេអូរហូត គេឲ្យកាន់អាហ្នឹងព្រោះសភាពការណ៍វាអត់ស្រួល បើសិនជាគេប៉ះសេពីមុខម៉ោខ្មាំងឡើងអញ្ចេះអញ្ចោះ អញ្ចឹងទៅខ្ញុំក៏រៀបរាប់ប្រាប់ថាអញ្ចេះអញ្ចុះសភាពការយើងអត់ស្រួល ប្រជាពលរដ្ឋយើងត្រូវដកថយ បើមានការឃោសនាគេយ៉ាងណាយ៉ាងណីខ្ញុំគេថាខ្ញុំហ្នឹងផ្ទៃក្នុងហើយសម្លាប់ឯងទៀត?

ដានី៖ ចុះគាត់នៅតាកែវម៉េចបានជាគាត់ម៉ោក្តាប់នៅស្រុកថ្មពួកទៅវិញ?

ឆន៖ អាហ្នឹងកាលហ្នឹងគេរើសភូមិភាគ ភូមិនេះសម្លាប់អានោះហើយភូមិភាគនោះសម្លាបភូមិនោះ វាចេះតែដាក់វាយកម៉ោពីភូមិភាគនារតីហ្នឹង ។

ដានី៖ អញ្ចឹងពេលណាបានតាយនគាត់ចេញ?

ឆន៖ គាត់ចេញកាល៨០ប៉ុន្មានទេ កាលគេយកចេញមិនទាន់កើតទេនៅ៨៨,៧៨៨នៅឡើយ?

ដានី៖ គាត់ចេញទៅណាទៅ?

ឆន៖ គេយកសូ ហុងម៉ោជំនួសវិញ សូ ហុង នឹងឡុង ថែម ដល់ហើយយកពួកហ្នឹងម៉ោដាក់ម៉ោមិនយកគាត់ម៉ោនៅ គេយកម៉ោនៅហ្នឹងគេយកមកដាក់យើងនៅសម័យ ។

ដានី៖ តែឥលូវគាត់នៅណាតាយន?

ឆន៖ គាត់ស្លាប់ហើយ ។

ដានី៖ គាត់ស្លាប់ស្លាប់ហើយ?

ឆន៖ បាទ!

ដានី៖ ស្លាប់ដោយសារអីគេ?

ឆន៖ ស្លាប់ដោយសារផ្ទុះមីន ។

ដានីៈ ដោយសារផ្ទុះមីន?

ឆនៈ បាទ! នៅសម្ពត ។

ដានីៈ អ៊ំនៅសម្ពត?

ឆនៈ បាទ! ខ្ញុំគេហៅតែរហូតហ្នឹង អាប្អូនហ្នឹងវាហៅឲ្យទៅរហូត?

ដានីៈ ឲ្យទៅនៅណា?

ឆនៈ ឲ្យទៅនៅសម្ពត ហើយខ្ញុំថាអត់ទេកូនអញនៅតូចណាស់ អញទៅពិបាកលក់ដី លក់ស្រែ រាល់ថ្ងៃជំរុញឲ្យកូនរៀន ឥលូវជំរុញឲ្យកូនមួយទៅរៀនផ្នែកក្រសួងតែមិនដឹងយ៉ាងម៉េចទេព្រោះរៀនមិនទាន់ចប់ផង ហើយមិនទាន់ឃើញហៅទៀត ។

ដានីៈ ចុះពូកាលហ្នឹងគេបញ្ជូនលោកសូ ហុង, ឡុង ថៃមម៉ោកងពល៥១៩ហ្នឹង?

ឆនៈ បាទ!

ដានីៈ ពីណាគេបញ្ជូនម៉ោ?

ឆនៈ អ៊ំ!

ដានីៈ អ៊ំណា?

ឆនៈ អ៊ំ៨៧ ។

ដានីៈ អ៊ំអៀង សារីហ្នឹង?

ឆនៈ អ៊ំពត ។

ដានីៈ អ៊ំពតហ្នឹង៨៧?

ឆនៈ បាទ!

ដានីៈ ចុះអៀង សារី៨០ប៉ុន្មាន?

ឆនៈ អៀង សារីដូចជាមិនដែលមានអ្នកណាហៅលេខទេ គេហៅតែអៀង សារីៗព្រោះគាត់មិនដែលនៅនេះណា៎គាត់នៅតែបរទេស ។

ដានីៈ ចុះសុន សេន?

ឆនៈ សុន សេនគេហៅអីទេ ខ្ញុំភ្លេចបាត់ហើយព្រោះកាលហ្នឹងខ្ញុំមិនសូវដែលបានទៅជិតនោះទេ ។

ដានីៈ ៨៧ប៉ុល ពត?

ឆនៈ អ៊ំមិនមែន៨៧ទេ គឺជំណាក់៨៧០ ។

ដានីៈ ចុះសូ ហុងខ្សែគាត់?

ឆនៈ គាត់អ្នកកំពង់ធំ ។

ដានីៈ សូ ហុងអ្នកកំពង់ធំ?

ឆនៈ បាទ!

ដានីៈ ចំណាស់ណាសូ ហុង?

ឆនៈ ប្រហែលជាខ្ទង់៦០ហ្នឹង ។

ដានីៈ ខ្ទង់៦០ ចុះឡុង ថែម?

ឆនៈ ឡុង ថែមក្រឡាប់ឡានស្លាប់កាលទៅជាមួយព្រំ ស៊ូ ។

ដានីៈ ព្រំ ស៊ូ?

ឆនៈ បាទ!

ដានីៈ ចុះឡុង ថែមគេអត់សូវចូលចិត្តគាត់ទេ?

ឆនៈ ឡុង ថែមមនុស្សវាក្មេង ។

ដានីៈ ក្មេង?

ឆនៈ បាទ! មនុស្សវាក្មេង មនុស្សវាអត់ស្គាល់សមរភូមិ វាអត់ស្គាល់រាក់ជ្រៅក្នុងការដឹកនាំ ម៉ោនេះសុទ្ធតែ៥១៩អញ្ចេះ ៥១៩អញ្ចោះ ម៉ោខ្លួនឯងដើរយកប្រពន្ធគេ ។

ដានីៈ ម៉េចអញ្ចឹង?

ឆនៈ អាថែមហ្នឹងដើរយកប្រពន្ធគេ ។

ដានីៈ ទៅយកប្រពន្ធគេ?

ឆនៈ ហើយទៅថ្វាយបន្តិចុល សារឿន សុទ្ធតែគេហ្នឹងមិនដល់ឯង ឯងហ្នឹងអ្នកច្បាស់លាស់ធ្វើឲ្យប៉ះពាល់នយោបាយអីអញ្ចេះអញ្ចោះ អាហ្នឹង៥១៩ណា៎ ។

ដានីៈ បាទ!

ឆនៈ បរិហារអញ្ចឹងទៅខាងលើគេស្តាប់មិនបាន ហើយខាងលើជឿតែសេចក្តីរាយការណ៍ហ្នឹង បើដាក់ស្តែងមិនដែលបានម៉ោ វាមិនខុសគ្នាជាមួយបក្សនោះទេ តែខ្ញុំអត់និយាយ ។

ដានីៈ បាទ!

ឆនៈ ដូចប៉ែន វយអី ប៉ែន វយធ្វើម៉េចហ៊ានហៅពួកខ្ញុំទៅកាលហ្នឹងយកទៅអត់មានកន្លែងដាក់ទេ ព្រោះគេដាក់តែបងប្អូនគេ ក្មេងៗយកមកធ្វើអីកើតសួទៅណាសាបតែក្របីអត់ដឹងផង សួសាកតែមាត់អត់ស្គាល់អីផង អានេះរឿងខាងលើគេបំបិទចោលអស់ហើយខ្និលមាត់ព្រោះអានេះរឿងរបស់គេ ។

ដានីៈ បាទ!

ឆនៈ ប៉ុន្តែពួកខ្ញុំមិនចោទមិនប្រកាន់ថាខាងនេះខាងនោះអីទេ ធ្វើម៉េចបើខ្ញុំមិនជឿបើកាលខ្ញុំចូលម៉ោ ផ្ទុកកូនតាហេងគាត់ហៅខ្ញុំបង ហើយទៅនិយាយស្ងាត់ក្នុងបន្ទប់របស់គាត់ ចង់ឲ្យបត់បែនទៅតាមគេ ហើយខ្ញុំថាបងឯងដើរកាត់ព្រៃស្ទានតែស្រួលណាស់អី បើគេឲ្យដើរតាមឲ្យផ្លូវម៉េចក៏មិនដើរ ដើរតាមផ្លូវគេទៅបងឯងទៅណាខ្ញុំទៅហ្នឹងដែរ ។

ដានីៈ ស្ងួន ចាន់ហេងគាត់នៅណា?

ឆនៈ នៅប៉ៃប៉ា ។

ដានីៈ នៅប៉ៃប៉ា?

ឆនៈ បាទ! ខ្ញុំអត់ដឹងជីវប្រវត្តិទេ តែកាលហ្នឹងសមារនៈកម្មហើយជួបគ្នា ។

ដានីៈ ពូសមារណៈកម្មឆ្នាំណាដែរ?

ឆនៈ សមារណៈកម្មកាល៩៧,៩៨ហ្នឹង ។

ដានីៈ មកពីខាងណាដែរពូ?

ឆនៈ ខ្ញុំម៉ោពីជប់គគី ។

ដានីៈ បាទ!

ឆនៈ គ្រាន់តែម៉ោនៅភូមិខាងជើងបន្ទាយឆ្មានេះគេថាឥលូវដកគ្រឿង ហើយខ្ញុំថាប្រគល់ឲ្យវិញគ្មានអ្នកណាគេចង់កាន់នោះទេ ។

ដានីៈ ដល់ចូលសមារណៈកម្មហើយពូទៅធ្វើទាហាននៅណាវិញ?

ឆនៈ ទាហានជាមួយបងហេងហ្នឹងចាប់តាំងពី កាលហ្នឹងគេឲ្យខ្ញុំហ្នឹងនៅឈរជើងនៅគោកកបិន នៅគោកកបិនហ្នឹង៩៨,៩៩,៨០ ហើយបោះឆ្នោតបោះអីហើយស្រួលបួលគេកាត់ពួកខ្ញុំនៅឆ្នាំ ២០០១ តាំងពី២០០១រហូតម៉ោដល់២០១០គេទើបតែកាត់បានថ្ងៃ២៨នេះឯង ។

ដានីៈ កាត់ថ្ងៃ២៨?

ឆនៈ ថ្ងៃ២៨ខែ១១នេះឯង ។

ដានីៈ ឥលូវពូចូលសោយធនហើយ?

ឆនៈ ពិការ ។

ដានីៈ ពិការ ពូនៅទាហាននៅស៊ុប ខេត្តបន្ទាយមានជ័យ?

ឆនៈ ខេត្តបន្ទាយមានជ័យ ។

ដានីៈ ពូមានតួនាទីអីដែរ?

ឆនៈ ខ្ញុំអត់ទេគេឲ្យធ្វើផ្នែកស្បៀងកាត់បេ ។

ដានី៖ ផ្នែកស្បៀងមានស័ក្តទេ?

ឆនៈ ត្រឹមក្បាលឯក ។

ដានី៖ ត្រឹមក្បាលឯក?

ឆនៈ បាទ! ខ្ញុំមិនចង់ធ្វើផងតែមេៗគាត់ថាធ្វើទៅ ខ្ញុំធ្វើតែយុទ្ធជនធម្មតា ។

ដានី៖ ចុះពូម៉ោដល់សព្វថ្ងៃនេះពូមានដែលព្ទពត៏មានទាក់ទងនឹងតុលាកាក្តីគេកាត់ទោសមេដឹកនាំខ្មែរក្រហមហើយនឹងឌុចអីទេ?

ឆនៈ ឮ!

ដានី៖ ហើយពូយល់យ៉ាងម៉េចដែរពេលគេកាត់ទោសតាឌុចថ្មីៗនេះ?

ឆនៈ ទេខ្ញុំមិនមានបញ្ហាអីនោះទេពីព្រោះរាល់ទង្វើទាំងអស់ អានេះគេហៅថាការដែលយល់មិនដល់ណាំ ។

ដានី៖ បាទ!

ឆនៈ ព្រោះកាលដែលគាត់នៅមានអំណាច ពួកខ្ញុំដើរជិតកន្លែងគេមិនបានទេ ។

ដានី៖ អញ្ចឹង?

ឆនៈ បាទ! មិនធម្មតាទេ មិនត្រឹមតែយោយោប៉ុណ្ណឹងទេសូម្បីតែរបៀបរបបរស់នៅរបស់គេគឺមិនឲ្យយើងទៅជិតទេ និយាយរួមគេហៅគាព្រយដែលគេដាក់អង់តែន ហើយឲ្យតែឃើញអាសេ២៥ឡើងទៅលើអញ្ចឹងហើយ ជុំវិញហ្នឹងកន្ទះគីឡូអត់មានអ្នកណាហ៊ានដើរទេ ។

ដានី៖ អត់មានអ្នកណាហ៊ានដើរទេ?

ឆនៈ បាទ! កងអន្តភាពដទៃៗដើរម៉ោនៅត្រឹម៥០០ម៉ែត្រឬក៏កន្ទះគីឡូអញ្ចឹងយើងមើលទៅឃើញគេចហើយអត់ហ៊ានដើរចូលទេ មិនធម្មតាទេអំណាចគេសំបើមណាស់ ដល់ពេលអញ្ចឹងទៅពួកខ្ញុំមិនហ៊ានទេ ហើយខ្ញុំមិនសូវចង់ខ្វល់ទេ ពីព្រោះអីបានជាខ្ញុំថាអញ្ចឹងពួកហ្នឹងបើសិនជានៅសម័យតស៊ូជាសម័យអាច់កំបាំង ហើយសម័យតស៊ូក៏គេយកបងប្អូនគេទៅធ្វើដែរគេមិនយកយើងទៅធ្វើទេព្រោះគេខ្លាចយើងគេមិនទុកចិត្តយើង ពួកនេះមិនមែនធម្មតាទេ អញ្ចឹងបានថាមិនងាយទេដូចសម្តេចនាយកគាត់មានប្រសាសន៍ហ្នឹងត្រូវហើយ សម្តេចនាយកក៏ខ្ញុំស្គាល់ ដល់ពេលគាត់អញ្ចឹងអ្នកណាហ៊ានទៅជិតគាត់ ។

ដានី៖ ស្គាល់គាត់ពីអន្កាល់?

ឆនៈ ស្គាល់កាលគាត់នៅភ្នំពេញ ។

ដានី៖ កាលគាត់នៅភ្នំពេញ?

ឆនៈ	បាទ!

ដានីៈ	គាត់នៅភ្នំពេញនៅឆ្នាំណា?

ឆនៈ	គាត់នៅសម័យខ្មែរក្រហមហ្នឹង។

ដានីៈ	អញ្ចឹង?

ឆនៈ	ម៉ាសម័យគាត់ម៉ោធ្វើគណៈចាត់របស់គណៈរបស់៨៧០ ពីភូមិភាគ ពីតំបន់ ស្រុក កន្លែងទៅរៀនសូត្រអីមានអ្នកណាបង្រៀន តែនេះប៉ុល ពតមិនស្រួលខ្លួនសម្តេចនាយកចូល កាលហ្នឹង មិនដឹងគេដាក់ឈ្មោះគាត់ឈ្មោះអីព្រោះកន្លែងអត់មានអ្នកណាហ៊ានទៅជិតទេ ព្រោះខ្ញុំនៅយាមពោធិ៍ចិនតុង។

ដានីៈ	ចុះពូធ្លាប់និយាយរឿងនៅពោធិ៍ចិនតុងទេ?

ឆនៈ	ដែល។

ដានីៈ	ធ្វើអីនៅពោធិ៍ចិនតុងហ្នឹង?

ឆនៈ	ធ្វើកងទ័ព?

ដានីៈ	ធ្វើកងទ័ពពៅ ហើយនៅកងពលណា?

ឆនៈ	ពីដើមហ្នឹងវាមានកងពលពីដើមកងពលទី១ហ្នឹងដែរ គេដាក់ពួកវរសេនាធំ១៧។

ដានីៈ	អញ្ចឹង?

ឆនៈ	អាហ្នឹងកងតាវេត។

ដានីៈ	តាវេតហ្នឹងកងពលទី១

ឆនៈ	បាទ!

ដានីៈ	មិនមែន៥០២ទេ?

ឆនៈ	អត់ទេ ៥១២ដែលយើងឈ្នះ១៧មេសាអីហ្នឹង។

ដានីៈ	បាទ!

ឆនៈ	៥១២គេកាន់កាលហ្នឹងវៃគ្នានៅព្រំដែន បង្កើត៥១២, ១៦៤ហើយពួកខ្ញុំគេយកបញ្ចូលហ្នឹងបានដឹកបាន គេដកពីកងពលទៅគេបញ្ចូលនៅ១៦៤ ចេញពី១៦៤ហ្នឹងបានដឹកកាត់ប្រទេសគេដឹកមនុស្សផ្សេង ដឹកកាំភ្លើងផ្សេង។

ដានីៈ	ហើយពូយល់យ៉ាងម៉េចដែរចំពោះតុលាកាកាត់ទោសមេដឹកនាំជាន់ខ្ពស់មេដឹកនាំខ្មែរក្រហម ហើយពូគិតឃើញយ៉ាងម៉េចដែរត្រូវឬខុស បើតាមចិត្តពូវិញ?

ឆនៈ អាហ្នឹងបើចិត្តរបស់ខ្ញុំវាមិនមានបញ្ហាអីដែលថាមិនត្រឹមត្រូវទេ ពីព្រោះបើសិនជាយើងមិនធ្វើត្រៀមមិនរៀបចំឯកសារនេះហើយការកាត់ទោសនេះឲ្យគាត់មានទំងន់អញ្ចឹងខ្លាចអ្នកដឹកនាំក្រោយទៅគេធ្វើទៅតាមរបៀបនេះណា៎ ។

ដានីៈ បាទ!

ឆនៈ អាហ្នឹងល្អដែរតើការដែលដាក់ការកាត់ទោស តែធ្វើយ៉ាងណាកុំឲ្យអន្តរជាតិគេថាមិនស្គាល់ខ្មែរសម្លាប់តែខ្មែរគ្នាឯង សម្លាប់តែពូជសាសន៍ខ្លួនឯង ។

ដានីៈ អញ្ចឹងពូខ្ញុំដូចជាអស់សំនួរត្រូវសួនាំពូទៀតហើយពូមានអីចង់បន្ថែមនៅអ្វីដែលខ្ញុំអត់ទាន់បានសួរនាំពូទេ?

ឆនៈ ទេអត់មានអីទេខ្ញុំ តែសំនូមពរបើសិនជាថាលោកគ្រូអាចមានលទ្ធភាពផ្តល់ជាមតិយោបល់អីទៅឲ្យថ្នាក់ដឹកនាំខាងលើហ្នឹងឲ្យដឹងឲ្យពូឲ្យទទួលស្គាល់ពួកដែលវាសមារណៈកម្មហ្នឹងធ្វើម៉េចចែកឲ្យវារស់ផង ដូចពួកខ្ញុំអីដែលម៉ោនេះអត់មានអីទេដៃទទេសុទ្ធគ្មានម៉ោទាមទាស្អីទេ ឲ្យរស់គឺរស់បើមិនឲ្យរស់គឺមិនរស់ ។

ដានីៈ ហើយពួកខ្ញុំនេះសួនាំលោកពូគឺដើម្បីយកទៅសរសេរផ្សព្វផ្សាយដូចជាទស្សនាវដ្តីស្វែងរកការពិត

ឆនៈ ពីព្រោះថាពួកខ្ញុំម៉ោមិនមានរដ្ឋាភិបាលអំពាវនាវឲ្យធ្វើសមារណៈកម្មអី អាហ្នឹងគេអនុវត្តគោលនយោបាយឈ្នះៗ ស្រលាញ់ណាស់ហើយពេញចិត្តចូលរួមធ្វើទៀតព្រោះអីវាមានផលប្រយោជន៍ដល់ជាតិ ។

ដានីៈ បាទ!

ឆនៈ បើធ្វើកន្លងមកវាអត់មានជាតិអីទេ ដូចជាការដែលខ្ញុំមកនៅនេះហើយទទួលការងារជាមេភូមិអញ្ចឹងលោកគ្រូពិចារណាមើលទៅ ប៉ះដីនេះខ្ញុំសួទៅឃុំទៅស្រុកអីគេអត់ឆ្លើយ ខ្ញុំបន់ឲ្យតែសម្តេចនាយកមកសម្ភោធបន្ទាយទាហាននេះទេ ទៅជួបគាត់ហើយ ខ្ញុំសួថាកសិករបើអត់មានស្រែគេហៅថាកសិករទេ ខ្ញុំសួតែប៉ុណ្ណឹងទេអត់មានអីច្រើនទេ ហើយបើសិនជាកសិករអត់មានដីអត់មានស្រែសួថាកសិករហ្នឹងរស់ដែរឬអត់ គឺមិនរស់ទេ ខ្ញុំចង់ឲ្យគាត់សម្បទានទោះបីកន្លែងក៏ដោយឲ្យតែថាដីអាចសម្បទានបានឲ្យប្រជាជនខ្ញុំរស់ផង ដូចលោកគ្រូអញ្ជើញម៉ោឃើញស្រាប់ហើយណែនប៉ែស៨០០គ្រួសារ ៨០០គ្រួសារដល់ពេលវង្វេងគ្នាម៉ោអានេះអញ្ចេះអានោះអញ្ចោះ អាណាវាអុកឡុកទៅអញ្ចឹងយើងក៏មានការផ្លាស់ប្តូរដែរ ស៊ូបានរស់ បើស៊ូមិនទេអត់ទៅ តែវាគ្មានស្អីសោះមើល អាហ្នឹងមិនមែននេះទេក្រោលគោទេអាហ្នឹងនោះ ក្រោលគោមើលឲ្យអ្នកថ្មពួកដល់ពេលគេយកគោទៅគេទុកក្រោលហ្នឹងឲ្យទៅ ហើយខ្ញុំយកកន្លែងហ្នឹង

ស្នាក់នៅគ្រាន់ឲ្យកូនរៀនសូត្រ មានតែប៉ុណ្ណឹងទេដំណាក់កាលនេះខ្ញុំចេះតែដាក់ទៅ ពេលដែលពួកគេម៉ោម្តងឲ្យគេអង្គុយកណ្តាលវាលដូចជាមិនសម ។

ដានី: អញ្ចឹងអរគុណច្រើនពូ ។

ឆន: បាទ!

«ចប់»